ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ :...១១១២...ន.ទ.ក.

# សេចក្តីណែនាំ

## ស្តីពី

## វិធានការលុបបំបាត់ស៊ីមកាតទូរស័ព្ទចល័ត ដែលគ្មានឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណ ផ្ទុយនឹងសារាចរអន្តរក្រសួងលេខ០០១ សរ.មផ-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២

ក្នុងស្មារតីទទួលខុសត្រូវខ្ពស់របស់ក្រសួងស្ថាប័នមានសមត្ថកិច្ច ដើម្បីលើកកម្ពស់ការការពារសន្តិសុខជាតិ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គមឱ្យកាន់តែល្អប្រសើរ ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានដាក់ចេញនូវសារាចរអន្តរក្រសួងលេខ០០១ សរ.មផ-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្ម និងការប្រើប្រាស់សេវាទូរគមនាគមន៍ ដោយបានណែនាំប្រតិបត្តិករទូរគមនាគមន៍ សាខាលក់ និងចែកចាយបន្តទាំងអស់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុត ក្នុងការតម្រូវឱ្យអ្នកជួលជាវសេវាទូរគមនាគមន៍បំពេញសំណុំបែបបទប្រើប្រាស់សេវា។

ដោយអនុលោមតាមការណែនាំដូចមានចែងនៅក្នុងខ្លឹមសារនៃសារាចរអន្តរក្រសួងខាងលើនេះ អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ អគ្គាធិការដ្ឋាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងនិយ័តករទូរគមនាគមន៍កម្ពុជា បានសម្របសម្រួល និងធ្វើការណែនាំបន្ថែម ព្រមទាំងផ្តល់ការពន្យារពេលអនុវត្តជាច្រើនដងរួចមកហើយ តែនៅមិនទាន់បានទទួលលទ្ធផលអនុវត្តប្រកបដោយប្រសិទ្ធភាពទាំងស្រុងពីបណ្តាប្រតិបត្តិករឡើយ ។

នាពេលចុងក្រោយនេះ ស្របតាមសេចក្តីរាយការណ៍របស់បណ្តាប្រតិបត្តិករផ្តល់សេវាទូរស័ព្ទចល័តនាកិច្ចប្រជុំថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីវឌ្ឍនៈភាពនៃការអនុវត្តសារាចរអន្តរក្រសួងលេខ០០១ សរ.មផ-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ និងសេចក្តីណែនាំក្រសួងស្ថាប័នមានសមត្ថកិច្ចនាពេលកន្លង និយ័តករទូរគមនាគមន៍កម្ពុជាបានពិនិត្យឃើញថា នៅមានស៊ីមកាតទូរស័ព្ទចល័តប្រមាណពី ៧ ទៅ ៨ ភាគរយទៀត ដែលមិនមានឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណ ។

ផ្អែកតាមស្មារតីនៃកិច្ចប្រជុំចុងក្រោយនាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ បានសម្រេចថា "ត្រឹមថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ គ្រប់ស៊ីមកាតរបស់បណ្តាប្រតិបត្តិករផ្តល់សេវាទូរស័ព្ទចល័តទាំងអស់ ត្រូវមានឯកសារសម្គាល់អត្តសញ្ញាណ"។ ដើម្បីសម្រេចបាននូវកម្មវិធីនេះ និយ័តករទូរគមនាគមន៍កម្ពុជា សូមធ្វើការណែនាំដល់គ្រប់ប្រតិបត្តិករទូរស័ព្ទចល័ត ភ្នាក់ងារចែកចាយបន្ត និងអ្នកប្រើប្រាស់សេវាទូរស័ព្ទចល័តទាំងអស់ ត្រូវអនុវត្តដូចខាងក្រោម៖

**ក) ចំពោះប្រតិបត្តិករផ្តល់សេវាទូរស័ព្ទចល័តទាំងអស់ រួមទាំងភ្នាក់ងារចែកចាយទាំងអស់ ៖**

**ក.១)** <u>ករណីស៊ីមកាតមិនទាន់ត្រូវបានប្រើប្រាស់ តែត្រូវបានបើកដំណើរការជាមុន (Pre-activate) និងចែកចាយដល់ភ្នាក់ងាររួច</u>

- ប្រតិបត្តិករត្រូវជូនដំណឹងតាមគ្រប់មធ្យោបាយដល់ភ្នាក់ងារលក់/ចែកចាយបន្តនូវគោលការណ៍ថ្មី ដែលត្រូវលុបបំបាត់ស៊ីមកាតណាដែលបានបើកដំណើរការជាមុន (Pre-activate) រួច និងលក្ខខណ្ឌកំណត់ "បើគ្មានឯកសារសម្គាល់អត្តសញ្ញាណទេ នោះនឹងពុំមានការបើកឱ្យដំណើរការ (Activate) ស៊ីមកាតឡើយ" ។

BR.

- ប្រតិបត្តិករត្រូវបិទដំណើរការ (Deactivate) នូវរាល់ស៊ីមកាតដែលបានបើកដំណើរការជាមុន (Pre-activate) រួចទាំងអស់ មកជាស៊ីមកាតធម្មតាវិញឱ្យបានមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

**ក.២)** <u>ករណីស៊ីមកាតកំពុងប្រើប្រាស់ តែគ្មានឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណ</u>

- ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៦ ប្រតិបត្តិករត្រូវរៀបចំជាសាររំលឹក (Announcement) ដល់អ្នកកំពុងប្រើប្រាស់ស៊ីមកាតដែលគ្មានឯកសារសម្គាល់អត្តសញ្ញាណ ឱ្យបាន ៧ ដង ក្នុងរយៈពេល ៧ ថ្ងៃ ដោយណែនាំឱ្យមកទាក់ទង និងផ្តល់ឯកសារពាក់ព័ន្ធនៅតាមការិយាល័យលក់របស់ប្រតិបត្តិករ និងភ្នាក់ងារចែកចាយបន្តទាំងអស់ ។
- ក្រោយពេលជូនដំណឹង ៧ ដងនេះរួច ប្រតិបត្តិករត្រូវធ្វើការផ្អាកដំណើរការមួយផ្លូវ (One-way Suspension) ដោយបិទការហៅចេញ និងផ្ញើសារ SMS ចេញ ចំពោះលេខដែលគ្មានឯកសារសម្គាល់អត្តសញ្ញាណទាំងអស់ ។
- បន្ទាប់ពីបិទការហៅចេញអស់រយៈពេល ៧ ថ្ងៃរួច ប្រសិនបើម្ចាស់ស៊ីមកាតនៅតែមិនមកចុះបញ្ជីឯកសារសម្គាល់អត្តសញ្ញាណទៀត ក្រុមហ៊ុនត្រូវធ្វើការបិទដំណើរការលេខនោះទាំងស្រុង (Full Suspension) ។
- ស្របតាមស្តង់ដាកំណត់របស់ ITU ក្នុងរយៈពេល ៣ ខែក្រោយការបិទដំណើរការ (Suspension) ម្ចាស់ស៊ីមកាតអាចបើកដំណើរការលេខនោះវិញ ប្រសិនម្ចាស់ស៊ីមកាតស្នើសុំ និងមានភ្ជាប់នូវឯកសារសម្គាល់អត្តសញ្ញាណត្រឹមត្រូវ ។ ក្រោយរយៈពេលបិទដំណើរការ ៣ ខែ បើសិនម្ចាស់ស៊ីមកាតពុំបានផ្តល់ឯកសារសម្គាល់អត្តសញ្ញាណ និងស្នើសុំបើកដំណើរការវិញទេ ប្រតិបត្តិករត្រូវលុបលេខទាំងនោះចេញពីប្រព័ន្ធចុះបញ្ជីស៊ីមកាត (HLR) របស់ខ្លួន ។

**ក.៣)** <u>ករណីការលក់ និងចែកចាយស៊ីមកាតថ្មី</u>

- ប្រតិបត្តិករ និងភ្នាក់ងារចែកចាយត្រូវបញ្ឈប់ជាដាច់ខាតរាល់ការចែកចាយ និងលក់ស៊ីមកាតទូរស័ព្ទដោយមិនយកឯកសារសម្គាល់អត្តសញ្ញាណរបស់អ្នកជាវ ទោះក្នុងរូបភាពណាក៏ដោយ ។ រាល់ការលក់ស៊ីមកាតថ្មីទាំងអស់ ប្រតិបត្តិករត្រូវបានទទួលឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណស្របតាមសារាចរអន្តរក្រសួងលេខ០០១ សរ.មផ-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ជាមុនសិន ទើបអាចធ្វើការបើកឱ្យដំណើរការ (Activate) សេវាបាន ។
- ដើម្បីពន្លឿននីតិវិធីនៃការបើកឱ្យដំណើរការ (Activate) សេវានេះ ប្រតិបត្តិករត្រូវអភិវឌ្ឍន៍កម្មវិធី (Application) ចុះបញ្ជីឯកសារសម្គាល់អត្តសញ្ញាណ ឬសហការជាមួយភ្នាក់ងារចែកចាយទាំងអស់ ដោយប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីអាចបញ្ជូនឯកសារសម្គាល់អត្តសញ្ញាណមកប្រតិបត្តិករសិន ទើបអាចបើកឱ្យដំណើរការស៊ីមកាត។

**ខ) ចំពោះអតិថិជន ឬអ្នកប្រើប្រាស់ ៖**

**ខ.១)** ចំពោះអតិថិជន ឬអ្នកប្រើប្រាស់ដែលកំពុងតែកាន់កាប់ស៊ីមកាតទូរស័ព្ទចល័តដែលមិនបានផ្តល់អត្តសញ្ញាណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់ខ្លួន ត្រូវសហការ ឬធ្វើការទំនាក់ទំនងជាមួយបណ្តាប្រតិបត្តិករផ្តល់សេវាទូរស័ព្ទដែលខ្លួនបានជាវកន្លងមក មិនឱ្យលើសថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាកំហិត ។ ក្នុងករណីមិនបានអនុវត្តក្នុងកាលបរិច្ឆេទនេះទេ និយ័តករទូរគមនាគមន៍កម្ពុជា នឹងមិនទទួលខុសត្រូវក្នុងការបាត់បង់សិទ្ធិ ឬការកាត់ផ្តាច់បណ្តាញប្រើប្រាស់ដោយប្រការនេះឡើយ។

**ខ.២)** ចំពោះអតិថិជន ឬអ្នកជាវបណ្តាញ ឬសេវាទូរស័ព្ទចល័តថ្មី ត្រូវផ្តល់អត្តសញ្ញាណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណស្របតាមសារាចរអន្តរក្រសួងលេខ ០០១ សរ.មផ.-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ រួមមាន ៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរមានសុពលភាព ចំពោះប្រជាពលរដ្ឋទូទៅ
- លិខិតសម្គាល់ខ្លួនចេញដោយក្រសួង ស្ថាប័ន អង្គភាពសាមី មានសុពលភាព ចំពោះមន្ត្រីរាជការ

- សង្ឃដីកាមានសុពលភាព ចំពោះព្រះសង្ឃ
- ដោយឡែកចំពោះអនិតិជន ត្រូវឱ្យឪពុកម្ដាយ ឬអាណាព្យាបាល ជាអ្នកផ្ដល់ជាំឱ្យ
- លិខិតឆ្លងដែន ភ្ជាប់នឹងទិដ្ឋាការស្នាក់នៅ មានសុពលភាព ចំពោះជនបរទេស
- លិខិតទទួលស្គាល់ផ្លូវការរបស់ស្ថានទូត អង្គការ សមាគម អង្គភាព ក្រុមហ៊ុន ដែលមានបំណងយក ប្រើប្រាស់រួម និងកំណត់ឱ្យបានច្បាស់លាស់ពីការទទួលខុសត្រូវរបស់បុគ្គល ចំពោះស្ថានទូត អង្គការ សមាគម អង្គភាព ក្រុមហ៊ុន ។

ក្រោយកាលបរិច្ឆេទកំណត់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ គណៈកម្មការអន្តរក្រសួងនឹងចុះត្រួតពិនិត្យផ្ទៀងផ្ទាត់នៅតាមមជ្ឈមណ្ឌលទូរស័ព្ទចល័តរបស់បណ្ដាប្រតិបត្តិករអំពីព័ត៌មានអត្តសញ្ញាណនៃស៊ីមកាតទាំងអស់។ ជាមួយគ្នានេះ អាជ្ញាធរមានសមត្ថកិច្ចនឹងចុះសាកល្បងទិញស៊ីមកាត នៅតាមបណ្ដាហាងលក់/ចែកចាយស៊ីមកាតបន្តទាំងអស់នៅទូទាំងប្រទេស ដើម្បីតាមដាន និងធានាបានថា នឹងពុំមានការលក់/អាចដំណើរការស៊ីមកាតដោយពុំមានឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណទៀតឡើយ ។

ទទួលបានសេចក្ដីណែនាំនេះ សូមប្រតិបត្តិករផ្ដល់សេវាទូរស័ព្ទ ភ្នាក់ងារចែកចាយ ឬលក់បន្ត អ្នកប្រើប្រាស់ទាំងអស់ មេត្តាចូលរួមសហការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។៚

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦

**ប្រធាន**

TELECOMMUNICATION REGULATOR OF CAMBODIA

**ម៉ៅ ចរិយា**

**<u>ចម្លងជូន</u>**
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- ប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ